# ព្រះរាជក្រម

នស/រកម/០១២០/០០១

# យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា១៧ មាត្រា២០ មាត្រា២១ មាត្រា២៧ មាត្រា២៨ មាត្រា២៩ មាត្រា៥៤ មាត្រា៥៥ និងមាត្រា៥៩ នៃច្បាប់ស្តីពីសហជីពដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១៦/០០៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៩ នាសម័យប្រជុំពេញអង្គលើកទី៤ នីតិកាលទី៤ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ០៣៧/០០៣/២០១៩ កបធ.ច ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

# ច្បាប់

## ស្ដីពី

## វិសោធនកម្មមាត្រា៣ មាត្រា១៧ មាត្រា២០
## មាត្រា២១ មាត្រា២៧ មាត្រា២៨ មាត្រា២៩
## មាត្រា៥៤ មាត្រា៥៥ និងមាត្រា៥៩
## នៃច្បាប់ស្ដីពីសហជីពដែលត្រូវប្រកាស
## ឲ្យប្រើដោយព្រះរាជក្រមលេខ
## នស/រកម/០៥១៦/០០៧
## ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៦

**មាត្រាមួយ .-**

មាត្រា៣ មាត្រា១៧ មាត្រា២០ មាត្រា២១ មាត្រា២៧ មាត្រា២៨ មាត្រា២៩ មាត្រា៥៤ មាត្រា៥៥ និងមាត្រា៥៩ នៃច្បាប់ស្តីពីសហជីពដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១៦/០០៧ ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០១៦ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ៖

**មាត្រា៣ .-ថ្មី វិសាលភាព**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះសហគ្រាសឬគ្រឹះស្ថាននិងជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**មាត្រា១៧ .-ថ្មី ការរក្សាបញ្ជិកា**

ដើម្បីរក្សាបញ្ជិកាដែលបានយល់ព្រមរួចហើយឲ្យនៅមានសុពលភាព សហជីព ឬសមាគមនិយោជកនីមួយៗត្រូវ៖

ក- ធ្វើរបាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍សកម្មភាពប្រចាំឆ្នាំ ដោយផ្អែកលើសៀវភៅហិរញ្ញវត្ថុនិងកំណត់ត្រាដែលបានរក្សាទុក ជូនគ្រប់សមាជិករបស់ខ្លួនជ្រាប យ៉ាងយូរត្រឹមដំណាច់ខែមីនានៃឆ្នាំបន្ទាប់ និងត្រូវធ្វើសវនកម្មដោយស្ថាប័នសវនកម្មឯករាជ្យដែលបានចុះបញ្ជីស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ក្នុងករណីមានការស្នើសុំពី៖

- សមាជិកចាប់ពី១០%(ដប់ភាគរយ)នៃចំនួនសមាជិកសរុបឬម្ចាស់ជំនួយណាមួយ ចំពោះសហជីពមូលដ្ឋាននិងសមាគមនិយោជក
- សមាជិកចាប់ពី៥%(ប្រាំភាគរយ)នៃចំនួនសមាជិកសរុបឬម្ចាស់ជំនួយណាមួយ ចំពោះសហព័ន្ធសហជីព សហភាពសហជីព និងសហព័ន្ធនិយោជក។

របាយការណ៍ទាំងនេះត្រូវបង្ហាញនូវ៖

- ប្រាក់ចំណូលសរុបដែលមាននៅក្នុងអំឡុងពេលគ្របដណ្តប់ក្នុងរបាយការណ៍ដោយបង្ហាញចំនួនទឹកប្រាក់ទៅតាមគ្រប់ប្រភពចំណូលទាំងអស់
- ការចំណាយផ្សេងៗរបស់សហជីពឬសមាគមនិយោជក
- សកម្មភាពរបស់សហជីពឬសមាគមនិយោជក
- ចំនួនសមាជិក។

ខ- សហជីពនិងសមាគមនិយោជកត្រូវផ្តល់រាល់ព័ត៌មានគណនីធនាគាររបស់ខ្លួនក្នុងរយៈពេល៤៥(សែសិបប្រាំ)ថ្ងៃ គិតពីថ្ងៃទទួលបានការចុះបញ្ជី។

គ- ធ្វើបច្ចុប្បន្នកម្មព័ត៌មានដែលតម្រូវឲ្យផ្តល់នៅក្រោមច្បាប់នេះនិងនៅពេលដែលមានការផ្លាស់ប្តូរណាមួយ ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ លើកលែងតែការផ្លាស់ប្តូរចំនួនសមាជិកភាព។

**មាត្រា២០ ._ថ្មី លក្ខខណ្ឌសម្រាប់អ្នកដឹកនាំគ្រប់គ្រងនិងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាល របស់សហជីពនៅក្នុងសហគ្រាសឬគ្រឹះស្ថាន**

អ្នកដឹកនាំគ្រប់គ្រងនិងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលរបស់សហជីព ដែលជាពលរដ្ឋខ្មែរត្រូវបំពេញលក្ខខណ្ឌដូចតទៅ៖

ក-  មានអាយុយ៉ាងតិច១៨(ដប់ប្រាំបី)ឆ្នាំឬអនីតិជនដែលទទួលបានអត្តាធីនភាព។

ខ-  ធ្វើសេចក្តីប្រកាសផ្ទាល់ខ្លួនអំពីអាសយដ្ឋានរស់នៅច្បាស់លាស់និងស្របច្បាប់។

អ្នកដឹកនាំគ្រប់គ្រងនិងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលរបស់សហជីព ដែលជាជនបរទេសត្រូវបំពេញលក្ខខណ្ឌដូចតទៅ៖

ក-  មានអាយុយ៉ាងតិច១៨(ដប់ប្រាំបី)ឆ្នាំឬអនីតិជនដែលទទួលបានអត្តាធីនភាព។

ខ-  ចេះអាននិងចេះសរសេរអក្សរខ្មែរ។

គ-  បាននិងកំពុងធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជាយ៉ាងតិច២(ពីរ)ឆ្នាំ។

ឃ-  មានសិទ្ធិស្នាក់នៅនិងមានទីលំនៅអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រឹមត្រូវតាមច្បាប់ស្តីពីអន្តោប្រវេសន៍នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២១ ._ថ្មី លក្ខខណ្ឌសម្រាប់អ្នកដឹកនាំគ្រប់គ្រងនិងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាល របស់សមាគមនិយោជក**

អ្នកដឹកនាំគ្រប់គ្រងនិងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលរបស់សមាគមនិយោជក ដែលជាពលរដ្ឋខ្មែរ ត្រូវបំពេញលក្ខខណ្ឌដូចតទៅ៖

ក-  មានអាយុយ៉ាងតិច១៨(ដប់ប្រាំបី)ឆ្នាំ។

ខ-  ធ្វើសេចក្តីប្រកាសផ្ទាល់ខ្លួនអំពីអាសយដ្ឋានរស់នៅច្បាស់លាស់និងស្របច្បាប់។

និយោជកដែលជាជនបរទេសអាចឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើសជាអ្នកដឹកនាំគ្រប់គ្រងនិងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលរបស់សមាគមនិយោជក ត្រូវបំពេញលក្ខខណ្ឌដូចតទៅ៖

ក-  មានអាយុយ៉ាងតិច១៨(ដប់ប្រាំបី)ឆ្នាំ។

ខ-  មានសិទ្ធិស្នាក់នៅនិងមានទីលំនៅអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រឹមត្រូវតាមច្បាប់ស្តីពីអន្តោប្រវេសន៍នៃព្រះរាជាណាចក្រកម្ពុជា។

គ-  បានវិនិយោគឬធ្វើការយ៉ាងតិច២(ពីរ)ឆ្នាំជាប់គ្នាក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២៧ ._ថ្មី ការថែរក្សាកំណត់ត្រាហិរញ្ញវត្ថុ**

សហជីពឬសមាគមនិយោជកទាំងអស់ ត្រូវរក្សាទុកនូវកំណត់ត្រាហិរញ្ញវត្ថុស្របតាមទម្រង់បែបបទដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ ហើយត្រូវបង្ហាញរបាយការណ៍ហិរញ្ញវត្ថុនេះទៅដល់សមាជិកនៃសហជីពឬសមាគមនិយោជក ស្របទៅតាមលក្ខន្តិកៈនៃសហជីពឬសមាគមនិយោជកនោះ និងត្រូវធ្វើសវនកម្មដោយស្ថាប័នសវនកម្មឯករាជ្យដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ក្នុងករណីមានការស្នើសុំពី៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរម៉េរាជវាំង

- សមាជិកចាប់ពី១០%(ដប់ភាគរយ)នៃចំនួនសមាជិកសរុបឬម្ចាស់ជំនួយណាមួយ ចំពោះសហជីពមូលដ្ឋាននិងសមាគមនិយោជក

- សមាជិកចាប់ពី៥%(ប្រាំភាគរយ)នៃចំនួនសមាជិកសរុបឬម្ចាស់ជំនួយណាមួយ ចំពោះសហព័ន្ធសហជីព សហភាពសហជីព និងសហព័ន្ធនិយោជក។

**មាត្រា២៨ .-ថ្មី ការរំលាយសហជីពឬសមាគមនិយោជក**

សហជីពឬសមាគមនិយោជកអាចត្រូវបានរំលាយតាមវិធីណាមួយ ដូចខាងក្រោម៖

១- សហជីពឬសមាគមនិយោជកមួយត្រូវបានរំលាយដោយអនុលោមតាមលក្ខន្តិកៈរបស់សហជីពឬសមាគមនិយោជកនីមួយៗ។

២- សហជីពមួយត្រូវបានរលាយដោយស្វ័យប្រវត្តិក្នុងករណីដែលសហគ្រាសឬគ្រឹះស្ថានត្រូវបានបិទលែងដំណើរការជាស្ថាពរ និងបានទូទាត់ជាស្ថាពរនូវប្រាក់ឈ្នួលនិងប្រាក់អត្ថប្រយោជន៍ផ្សេងៗរបស់កម្មករនិយោជិត។

៣- សហជីពឬសមាគមនិយោជកត្រូវបានរំលាយចោលដោយតុលាការ។

**មាត្រា២៩ .-ថ្មី មូលហេតុនៃការរំលាយចោលដោយតុលាការការងារ**

ភាគីពាក់ព័ន្ធឬសមាជិកចំនួន៥០%(ហាសិបភាគរយ)នៃសមាជិកសរុបរបស់សហជីពឬសមាគមនិយោជក មានសិទ្ធិប្តឹងទៅតុលាការការងារដើម្បីរំលាយសហជីពឬសមាគមនិយោជកនោះ។

សហជីពឬសមាគមនិយោជកត្រូវបានរំលាយដោយតុលាការការងារនៅក្នុងមូលហេតុណាមួយដូចខាងក្រោម៖

ក- ការបង្កើតឬសកម្មភាពនានារបស់សហជីពឬសមាគមនិយោជក មានលក្ខណៈផ្ទុយនឹងច្បាប់ឬគោលដៅនៃសហជីពឬសមាគមនិយោជក ដូចមានចែងនៅក្នុងលក្ខន្តិកៈ។

ខ- សហជីពដែលមិនមានលក្ខណៈឯករាជ្យពីនិយោជកតទៅទៀត ហើយជាក់ស្តែងមិនអាចស្តារឡើងវិញនូវភាពឯករាជ្យរបស់ខ្លួន។

តុលាការការងារអាចកំណត់ពេលវេលាសម្រាប់ឲ្យសហជីពឬសមាគមនិយោជកធ្វើការកែតម្រូវកង្វះខាតទាំងឡាយដូចមានចែងក្នុងចំណុច"ក"និង"ខ"ខាងលើនេះ មុននឹងចេញសេចក្តីសម្រេចរបស់ខ្លួន។

**មាត្រា៥៤ .-ថ្មី ភាពជាតំណាងបំផុតនៅថ្នាក់សហគ្រាសឬគ្រឹះស្ថាន**

ភាពជាតំណាងបំផុតនៃសហជីពត្រូវបានទទួលស្គាល់នៅក្នុងក្របខ័ណ្ឌនៃសហគ្រាសឬគ្រឹះស្ថាន។ សម្រាប់គោលបំណងនៃការចរចាអនុសញ្ញារួមឬដោះស្រាយវិវាទការងាររួម គឺសហជីពដែលមានភាពជាតំណាងបំផុតទទួលបានសិទ្ធិផ្តាច់មុខ។

សហជីពមួយនឹងទទួលបានភាពជាតំណាងបំផុត លុះត្រាតែសហជីពនោះបានបំពេញគ្រប់លក្ខណវិនិច្ឆ័យដូចតទៅ៖

ក- បានចុះបញ្ជីត្រឹមត្រូវ។

ខ- មានកម្មវិធីនិងសកម្មភាពដែលបង្ហាញថាសហជីពនោះមានលទ្ធភាពផ្តល់សេវាខាងវិជ្ជាជីវៈ វប្បធម៌ និងអប់រំដល់សមាជិករបស់ខ្លួនដូចមានចែងនៅក្នុងច្បាប់នេះ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

គ-មានបញ្ជីសមាជិកដែលបានកាត់ប្រាក់ភាគទានច្រើនជាងគេឬទទួលបានការបោះឆ្នោតគាំទ្រច្រើនជាងគេនៅក្នុងសហគ្រាសឬគ្រឹះស្ថានមួយដូចករណីខាងក្រោម៖

- សហជីពដែលមានសមាជិកចាប់ពី៣០%(សាមសិបភាគរយ)នៃចំនួនកម្មករ និយោជិតសរុបនៅក្នុងសហគ្រាសឬគ្រឹះស្ថានដែលមានសហជីពតែមួយ ឬ
- សហជីពណាដែលស្វែងរកបានការគាំទ្រពីសហជីពដទៃច្រើនជាងគេបំផុតដោយលើសពី៣០%(សាមសិបភាគរយ)នៃចំនួនកម្មករនិយោជិតសរុបក្នុងសហគ្រាសឬគ្រឹះស្ថានដែលមានសហជីពលើសពី១(មួយ) ឬ
- ក្នុងករណីសហជីពណាមួយពុំអាចរកសមាជិកគាំទ្របានចាប់ពី៣០%(សាមសិបភាគរយ)នៃចំនួនកម្មករនិយោជិតសរុប ត្រូវរៀបចំការបោះឆ្នោតស្វែងរកការគាំទ្រឲ្យបានសំឡេងច្រើនជាងគេបំផុតលើសពី៣០%(សាមសិបភាគរយ)នៃចំនួនកម្មករនិយោជិតសរុបក្នុងសហគ្រាសឬគ្រឹះស្ថាននោះ។ បែបបទអនុវត្តនៃការបោះឆ្នោតត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ។

ប្រសិនបើនៅក្នុងសហគ្រាសឬគ្រឹះស្ថានមួយមានសហជីពមូលដ្ឋានច្រើនផ្សេងៗគ្នា មិនអាចបំពេញគ្រប់លក្ខណវិនិច្ឆ័យដូចមានចែងក្នុងកថាខណ្ឌខាងលើនៃមាត្រានេះ ហើយពុំអាចស្វែងរកការទទួលស្គាល់ភាពជាតំណាងបំផុតទេ ការចរចាចុះអនុសញ្ញារួមត្រូវតែអនុវត្តដាច់ខាតតាមមាត្រា៧២(ក្រុមប្រឹក្សាចរចា)នៃច្បាប់នេះ។

## មាត្រា៥៥ ..ថ្មី ភាពជាតំណាងបំផុតនៅក្នុងវិជ្ជាជីវៈមួយឬសកម្មភាពសេដ្ឋកិច្ចមួយឬវិស័យមួយ

នៅក្នុងវិជ្ជាជីវៈមួយ ឬសកម្មភាពសេដ្ឋកិច្ចមួយ ឬវិស័យមួយដែលមានសហជីពច្រើន សហជីពទាំងនេះត្រូវតែស្វែងរកការទទួលស្គាល់ភាពជាតំណាងបំផុត ដោយត្រូវបំពេញលក្ខណវិនិច្ឆ័យដូចមានចែងក្នុងចំណុច"ក"និង"ខ"នៃមាត្រា៥៤ថ្មី(ភាពជាតំណាងបំផុតនៅថ្នាក់សហគ្រាសឬគ្រឹះស្ថាន)នៃច្បាប់នេះ ដោយបូកបន្ថែមលក្ខណវិនិច្ឆ័យមួយទៀត គឺត្រូវមានបញ្ជីសមាជិកដែលបានកាត់ប្រាក់ភាគទានចាប់ពី ៣០%(សាមសិបភាគរយ)នៃចំនួនកម្មករនិយោជិតទាំងអស់នៅក្នុងវិជ្ជាជីវៈ ឬសកម្មភាពសេដ្ឋកិច្ច ឬវិស័យដែលសហជីពដាក់ពាក្យសុំបញ្ជាក់ភាពជាតំណាងបំផុត។

សហជីពដែលមានភាពជាតំណាងបំផុតមានសិទ្ធិផ្តាច់មុខក្នុងការតំណាងឲ្យកម្មករនិយោជិតទាំងអស់ដើម្បីធ្វើការចរចាចុះអនុសញ្ញារួមឬដោះស្រាយវិវាទការងាររួមជាមួយនិយោជកឬសមាគមនិយោជកនៃវិជ្ជាជីវៈ ឬសកម្មភាពសេដ្ឋកិច្ច ឬវិស័យនោះ។

ប្រសិនបើនៅក្នុងវិជ្ជាជីវៈមួយ ឬសកម្មភាពសេដ្ឋកិច្ចមួយ ឬវិស័យមួយមានសហជីពច្រើនផ្សេងៗគ្នាដែលមិនអាចបំពេញគ្រប់លក្ខណវិនិច្ឆ័យដូចមានចែងក្នុងកថាខណ្ឌខាងលើនៃមាត្រានេះ ហើយពុំអាចស្វែងរកការទទួលស្គាល់ភាពជាតំណាងបំផុតទេ ការចរចាចុះអនុសញ្ញារួមត្រូវតែអនុវត្តដាច់ខាតតាមមាត្រា៧២(ក្រុមប្រឹក្សាចរចា)នៃច្បាប់នេះ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា៥៩ .- ថ្មី សិទ្ធិនិងតួនាទីរបស់សហជីពដែលមានសមាជិកភាគតិចនៅក្នុងសហគ្រាស ឬគ្រឹះស្ថានជាមួយសហជីពដែលមានភាពជាតំណាងបំផុត**

សហជីពដែលមានសមាជិកភាគតិចទាំងឡាយនៅក្នុងសហគ្រាសឬគ្រឹះស្ថានដែលមានសហជីពមានភាពជាតំណាងបំផុតត្រូវបានបញ្ជាក់រួច ហើយដែលកំពុងស្ថិតនៅក្នុងសុពលភាព ត្រូវបានហាមឃាត់លើការទាមទារសិទ្ធិចរចាអនុសញ្ញារួមនិងការទាមទារសិទ្ធិឬអត្ថប្រយោជន៍ផ្សេងៗ ដែលលើសពីអត្ថប្រយោជន៍ចែងនៅក្នុងច្បាប់ បទបញ្ញា អនុសញ្ញារួមដែលកំពុងមានសុពលភាព ឬវិធានការងារផ្ទៃក្នុងទាំងឡាយ។ សិទ្ធិនិងតួនាទីរបស់សហជីពដែលមានសមាជិកភាគតិចរួមមាន៖

ក- ការផ្តល់វគ្គបណ្តុះបណ្តាលស្តីពីចំណេះដឹងផ្នែកច្បាប់និងវិជ្ជាជីវៈ។

ខ- ការផ្តល់ប្រឹក្សាផ្នែកច្បាប់និងការអនុវត្តជាក់ស្តែងដល់សមាជិករបស់ខ្លួន។

គ- ការធ្វើជាតំណាងសមាជិករបស់ខ្លួននៅក្នុងការដោះស្រាយវិវាទបុគ្គល។

ឃ- ការចូលរួមនៅក្នុងយន្តការកិច្ចសហការនៅកន្លែងការងារដែលប្រព្រឹត្តទៅជាប្រចាំ។

ង- ការចូលរួមប្រឹក្សាយោបល់នៅក្នុងយន្តការទីផ្សារការងារ។

ច- ការផ្តល់ព័ត៌មានពាក់ព័ន្ធនឹងសមាជិករបស់ខ្លួន។

ឆ- ការរៀបចំបង្កើតនូវសហករណ៍ដែលអាចជាហាងលក់ដូរគ្រឿងទំនិញ អាហារដ្ឋាន ឬការថែរក្សាសុខភាព។ល។ សម្រាប់សម្រួលដល់ជីវភាពរស់នៅរបស់សមាជិកខ្លួន។

ជ- តួនាទីផ្នែករដ្ឋបាលនៅក្នុងការផ្តល់ឲ្យនូវអត្ថប្រយោជន៍ដល់សមាជិករបស់ខ្លួនពេលគ្មានការងារធ្វើ។

ឈ- ការធ្វើជាតំណាងសមាជិករបស់ខ្លួននៅក្នុងការដោះស្រាយវិវាទការងាររួម ដែលមិនកើតចេញពីការអនុវត្តអនុសញ្ញារួម។

សហជីពមានភាពជាតំណាងបំផុតក៏អាចអនុវត្តតួនាទីដែលមានកំណត់ក្នុងចំណុច"ក"ដល់ចំណុច"ឈ"ខាងលើនេះដែរ។

**មាត្រាពីរ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញ្ញាប់។

ថ្ងៃ ព្រហស្បតិ៍ ៨កើត ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០២០

នស/រកម.០១២០.០០១

ន សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**